**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** :០៦ សរណន

រាជធានីភ្នំពេញ,ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៧

# សារាចរណែនាំ

## ស្តីពី

## ការអនុវត្តផែនការបែងចែកសម្បទានដីសង្គមកិច្ច

រាជរដ្ឋាភិបាលបានពិនិត្យឃើញថា ចាប់ពីប្រទេសជាតិបានទទួលសន្តិភាពពេញលេញដោយសារនយោបាយ **ឈ្នះ ឈ្នះ** បានធ្វើឲ្យសភាពការណ៍កម្ពុជាមានការរីកចំរើនយ៉ាងឆាប់រហ័ស។ សភាពការណ៍សេដ្ឋកិច្ចសង្គម ក្នុងនេះទីផ្សារដីមានការវិវត្តន៍ប្រែប្រួល យ៉ាងលឿន ធ្វើឲ្យដីធ្លីមិនគ្រាន់តែជាមធ្យោបាយផលិតកម្មប៉ុណ្ណោះទេ តែជាប្រភពធនធានហិរញ្ញវត្ថុយ៉ាងសំខាន់របស់ប្រជាពលរដ្ឋ ក្នុងការកែលំអជីវភាពរស់នៅ ក៏ដូចជាការវិនិយោគលើគ្រប់ផ្នែក។ ទន្ទឹមនេះ អត្រាកំណើនខ្ពស់នៃប្រជាពលរដ្ឋ និងការវិវត្តន៍ដ៏លឿននៃទីផ្សារដី បានធ្វើឲ្យមានតម្រូវការដីធ្លី សំរាប់សាងសង់លំនៅដ្ឋាន និង ប្រកបរបរកសិកម្ម ពិសេសចំពោះគ្រួសារក្រីក្រ និងយោធិនរំសាយ ក៏បានកើនឡើងដែរ ។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះរាជរដ្ឋាភិបាលបានចេញអនុក្រឹត្យ ស្តីពីសម្បទានដីសង្គមកិច្ច សំរាប់គាំទ្រដល់ការអនុវត្តគោលនយោបាយបែងចែកដីធ្លីប្រកប ដោយសមធម៌ ដូចដែលមានចែងក្នុងឯកសារបឋមស្តីក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោលបាយដីធ្លី ។ អនុវត្តនូវស្មារតីនៃអនុក្រឹត្យនេះ រាជរដ្ឋាភិបាលបានធ្វើការបែងចែកដី និងធ្វើនិយតកម្មការកាន់កាប់ដីធ្លីដោយប្រជាពលរដ្ឋក្រីក្រសំរាប់ប្រជាពលរដ្ឋរាប់ម៉ឺនគ្រួសារជាបន្តបន្ទាប់ ។

ដើម្បីជំរុញការអនុវត្តឲ្យបានជោគជ័យ នូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលក្នុងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ ដែលបានកំណត់ឲ្យជំរុញការបែងចែកដីសម្បទានសង្គមកិច្ច ដល់គ្រួសារក្រីក្រដែលខ្វះដី និងគ្មានដី ឲ្យបានយ៉ាងតិច ១០.០០០ គ្រួសារដល់ឆ្នាំ ២០០៨ រាជរដ្ឋាភិបានធ្វើការណែនាំ ដូចខាងមុខ ៖

១. អភិបាលគ្រប់ខេត្តក្រុង ដែលជាប្រធានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីខេត្តក្រុង ត្រូវរៀបចំផែនការបែងចែកដីសម្បទានសង្គមកិច្ច ទាំងការជ្រើសរើសដី ការធ្វើផែនការប្រើប្រាស់ដី និងការជ្រើសរើសមុខសញ្ញា អ្នកទទួលដីចាប់ពីពេលនេះរហូតដល់ពាក់កណ្តាលឆ្នាំ២០០៨ ក្នុង០១ ខេត្តក្រុង អោយបានយ៉ាងតិចជាមធ្យមសំរាប់៤១៦គ្រួសារ ។ ចំពោះខេត្តក្រុងណាដែលមានលទ្ធភាពដីច្រើន ត្រូវធ្វើការជ្រើសរើសដីឲ្យបានលើមធ្យមភាគខាងលើ ដើម្បីរួមចំណែកជួយដោះស្រាយដល់ខេត្តក្រុងដែលខ្វះដី។ ទន្ទឹមនឹងនេះត្រូវកសាងផែនការអភិវឌ្ឍន៍ទីតាំងបែងចែកដីសម្បទានសង្គមកិច្ចដើម្បីរៀបចំផែនការថវិកា ចំណាយបញ្ចូលក្នុងគំរោងថវិកាជាតិ ឆ្នាំ២០០៩ ។ ផែនការអភិវឌ្ឍន៍នេះត្រូវយកចិត្តទុកដាក់ជាសំខាន់ធ្វើឲ្យមានការប្រែប្រួលខាងជីវភាព និងសុខមាលភាពរបស់អ្នកទទួលដីសម្បទានសង្គមកិច្ចមានជាអាទិ៍ ប្រភពផ្គត់ផ្គង់ទឹក ផ្លូវថ្នល់ មណ្ឌលសុខភាព សាលារៀន ។ល។

២. គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ សហការជាមួយគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីណែនាំតម្រង់ទិសឲ្យគ្រប់ខេត្តក្រុង ស្រុកខណ្ឌ ឃុំសង្កាត់ អនុវត្តឲ្យបានត្រឹមត្រូវតាមស្មារតីនៃអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច។

៣ គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ត្រូវរាការណ៍តាមដំហានការងារ ជូនរាជរដ្ឋាភិបាល ស្តីពីលទ្ធផលនៃការអនុវត្តសារាចរនេះ។

ទទួលបានសារាចរណែនាំនេះ រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តក្រុង ស្រុកខណ្ឌ ក្រុមប្រឹក្សាគ្រប់ឃុំសង្កាត់ ត្រូវចាត់តាំងអនុវត្តតាមការណែនាំខាងលើ ដោយស្មារតីទទួលខុសត្រូវ និងប្រសិទ្ធភាព។

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

លេខ : ៦៧ .ដនស/អរប

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ,ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៧

**អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ប៉ែន-អ៊ុត**